Australian Government
AusAID

Cardno ACIL

# គំរោងតំបន់អាស៊ីដើម្បីទប់ស្កាត់ការជួញដូរមនុស្ស ARTIP

*កិច្ចផ្តួចផ្តើមរបស់រដ្ឋាភិបាលអូស្ត្រាលី*

Australian Government
AusAID

*កិច្ចផ្តួចផ្តើមរបស់រដ្ឋាភិបាលអូស្ត្រាលី*

Website: www.artipproject.org

Email: info@artipproject.org

Cardno ACIL

ទំនាក់ទំនងជាមួយយើងខ្ញុំ :

ការិយាល័យថ្នាក់តំបន់ និងការិយាល័យប្រទេសថៃឡង់:

1-7 Zuellig House, Unit 1A, 4th Floor, Silom Road,
Bangrak, Bangkok, Thailand 10500

Tel: +66 2 636 0531-3
Fax: +66 2 636 0534

ការិយាល័យប្រទេសកម្ពុជា :

ក្រសួងយុត្តិធម៌ អាស័យដ្ឋានលេខ: ១៤, ផ្លូវសុធារស, ភ្នំពេញ, កម្ពុជា

Tel/Fax: +855 23 990 810

ការិយាល័យប្រទេសភូមារ :

No. 80, Kanbawza Lane 2, Shwe Taung Gyar,
Bahan Township, Yangon, Myanmar

Tel: +95 1 513 171, 5
Fax: +95 1 513 150

ការិយាល័យប្រទេសឡាវ:

Immigration Department, Ministry of Public Security,
Ban Hatsady Tai, Chanthaboury District, Vientiane, Lao PDR

Tel: +856 21 262 609
Fax: +856 21 262 396







## សេចក្តីផ្តួចផ្តើមក្នុងការដោះស្រាយបញ្ហាជួញដូរមនុស្សនៅក្នុងតំបន់អាស៊ីរបស់រដ្ឋាភិបាលអូស្ត្រាលី

## ទស្សនះវិជ្ជារបស់គំរោង

ការឆ្លើយតបប្រកបដោយប្រសិទ្ធភាព របស់ប្រព័ន្ធយុត្តិធម៌ ព្រហ្មទណ្ឌ លើបញ្ហាជួញដូរមនុស្ស គឺជាការសំខាន់ដើម្បី បញ្ចប់ភាពគ្មានទោស នៃនិទណ្ឌភាពរបស់ជនជួញដូរមនុស្សនៅ ពេលបច្ចុប្បន្ន ស្របពេលគ្នានេះដែរ គឺធានាសុវត្ថិភាព និង យុត្តិធម៌ដល់អ្នកដែលត្រូវបានគេជួញដូរ ។ កិច្ចការនេះ រួមមាន ក្របខណ្ឌច្បាប់ខ្លាំង និងអាចអនុវត្តបាន, នគរបាល នៅថ្នាក់មូលដ្ឋាន និងនគរបាលឯកទេស មានសមត្ថភាព ព្រះរាជអាជ្ញា និងចៅក្រមមានការបណ្តុះបណ្តាល និងមាន ឆន្ទះ, ប្រព័ន្ធក្នុងការកំណត់អត្តសញ្ញាណជនរងគ្រោះឱ្យបាន ឆាប់ និងត្រឹមត្រូវ និងយន្តការជំរុញកិច្ចសហប្រតិបត្តិការ របស់ប្រព័ន្ធយុត្តិធម៌នៅក្នុងប្រទេស និងនៅតាមព្រំដែន នៅគ្រប់ដំណាក់កាលទាំងអស់ ការឆ្លើយតបចំពោះអំពើជួញ ដូរមនុស្ស នៅថ្នាក់ជាតិ និងតំបន់ គួរអនុវត្តតាមស្តង់ដារ ទទួលស្គាល់ជាលក្ខណៈអន្តរជាតិ ខាងផ្នែកប្រព័ន្ធព្រហ្មទណ្ឌ និងសិទ្ធិមនុស្ស ។

## ប្រវត្តិរបស់គំរោង ARTIP

នៅឆ្នាំ ២០០៣, រដ្ឋាភិបាលអូស្ត្រាលី បានផ្តួចផ្តើមសម្ភោធ គំរោងថ្នាក់តំបន់មួយមានឈ្មោះថា កិច្ចសហប្រតិបត្តិការតំបន់ អាស៊ីដើម្បីទប់ស្កាត់ការជួញដូរមនុស្ស (ARCPPT) ។ គំរោងនេះ ត្រូវបានបញ្ចប់នៅខែសីហា ឆ្នាំ ២០០៦ បានសំរបសំរួលឱ្យមាន យុទ្ធសាស្ត្រប្រសិទ្ធភាព និងមានលក្ខណៈសំរបសំរួលជាងមុន ទាំងនៅក្នុងប្រទេស និងរវាងប្រទេសនានា ។

គំរោង ARCPPT បានធ្វើការជាមួយស្ថាប័នយុត្តិធម៌ព្រហ្មទណ្ឌ នៅក្នុងប្រទេសកម្ពុជា ឡាវ ភូមា និងថៃឡង់ និងអនុវត្ត សកម្មភាពមួយចំនួននៅប្រទេសឥណ្ឌូណេស៊ី ។ គំរោងបាន សហការយ៉ាងជិតស្និទ្ធជាមួយអាស៊ាន និងវេទិការថ្នាក់តំបន់ ស្តីពីការជួញដូរមនុស្ស រួមទាំង COMMIT ។

យោងតាមការពិនិត្យមើលការងាររបស់គំរោង ARCPPT គំរោងថ្មីមួយត្រូវបានសំរេចបង្កើតឡើង ដោយយោងតាម សមិទ្ធិផលនានាដែលទទួលបានពីប្រទេសនីមួយៗ និងតំបន់ ទាំងមូល ។








# កិច្ចផ្តួចផ្តើមរបស់រដ្ឋាភិបាលអូស្ត្រាលី ដើម្បីពង្រឹងការឆ្លើយតបលើអំពើជួញដូរមនុស្សនៅក្នុងតំបន់អាស៊ី

## គំរោង ARTIP គឺផ្តោតទៅលើការបញ្ចប់និទណ្ឌភាពរបស់ជនជួញដូរមនុស្ស និង ធានាយុត្តិធម៌ជូនជនរងគ្រោះ





## គំរោង

ARTIP បានចាប់ផ្តើមនៅខែសីហា ឆ្នាំ ២០០៦ សង្ឃឹមថា នឹងដំណើរការសំរាប់រយៈពេល៥ឆ្នាំ ។ ដូចគំរោងមុនដែរ គំរោង ARTIP នេះ គឺផ្តោតទៅលើការឆ្លើយតបលើបញ្ហា ជួញដូរមនុស្ស ដោយប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ដោយសង្កត់ ជាពិសេស លើការបញ្ចប់និទណ្ឌភាពជនជួញដូរមនុស្ស និង ការស្វែងរកយុត្តិធម៌ជូនជនរងគ្រោះ ។ គំរោង ARTIP បាន អនុវត្តសកម្មភាពជាដំបូងនៅប្រទេសកម្ពុជា ថៃ ឡាវ និង ភូមារ ។ សកម្មភាពគំរោងអាចនឹងពង្រីកដល់ប្រទេសអាស៊ាន ផ្សេងដទៃទៀត ជាពិសេស ឥណ្ឌូណេស៊ី នៅក្នុងរយៈពេល គំរោង ។ យន្តការពិសេសមួយត្រូវបានបង្កើតឡើង ដើម្បីជួយ កំណត់ការពង្រីកដល់ប្រទេសណាមួយ និងការដាក់បញ្ចូលទៅ ក្នុងប្រទេសគំរោងឱ្យទទួលបានជោគជ័យ ។

## ការពង្រឹងការឆ្លើយតបលើបញ្ហាជួញដូរមនុស្ស ដោយនគរបាលឯកទេស និងនគរបាលទូទៅ

ទាំងនគរបាលឯកទេស និងនគរបាលទូទៅ គឺជាចំណុចគន្លឹះ ក្នុងការឆ្លើយតបឱ្យបានខ្លាំងលើបញ្ហាជួញដូរមនុស្ស ។ ជូនកាល នគរបាលទូទៅ គឺជាអ្នកដែលបានទំនាក់ទំនងជាមួយជនរងគ្រោះ និងជនជួញដូរមនុស្សមុនគេ ហើយវាគឺជាការសំខាន់ណាស់ដែល នគរបាលទូទៅនេះ តំរូវឱ្យធ្វើការកំណត់អត្តសញ្ញាណជនរងគ្រោះ ឱ្យបានត្រឹមត្រូវ និងឆ្លើយតបលើបទល្មើសជួញដូរមុនគេ ។ នគរបាលឯកទេស គឺតំរូវឱ្យអនុវត្តសកម្មភាពស្មុគស្មាញ ប៉ុន្តែ វាគឺជាការងារសំខាន់ នៅក្នុងការស៊ើបអង្កេតបទល្មើសជួញដូរ មនុស្ស ។ គំរោង ARTIP មានគោលដៅផ្តល់ចំណេះដឹង និងជំនាញដល់សេចក្តីតំរូវការរបស់នគរបាលទូទៅ និងឯកទេស ។ គំរោងផ្តោតជាពិសេស លើការគាំទ្រអង្គភាពប្រឆាំងអំពើជួញដូរ មនុស្ស ព្រមទាំងជួយបង្កើតទំនាក់ទំនងរវាងអង្គភាពឯកទេស ទាំងនេះ ដើម្បីជំរុញកិច្ចសហប្រតិបត្តិការស៊ើបអង្កេតរវាង ប្រទេសនានា ។

## ការពង្រឹងការឆ្លើយតបលើបញ្ហាជួញដូរមនុស្ស ដោយអយ្យការ និងតុលាការ

ការងាររបស់គំរោង ARTIP នឹងបង្កើនចំណេះដឹង និង ការយល់ដឹងដល់ព្រះរាជអាជ្ញា និងចៅក្រមអំពីបញ្ហាជួញដូរមនុស្ស ដើម្បីធានាថា រឿងក្តីជួញដូរមនុស្សទទួលបានជោគជ័យក្នុងការ ចោទប្រកាន់ និងកាត់ក្តី ។ បន្ថែមលើការគាំទ្រថ្នាក់ជាតិ គំរោងនឹងបង្កើនសកម្មភាពគាំទ្រដល់កិច្ចសហប្រតិបត្តិការ ក្នុង ការចោទប្រកាន់រវាងប្រទេស និងប្រទេស ។

## ការពង្រឹងក្របខ័ណ្ឌច្បាប់ និងគោលនយោបាយ

ច្បាប់ល្អ គឺជាមូលដ្ឋានគ្រឹះនៃការឆ្លើយតបលើអំពើជួញដូរមនុស្ស ដ៏ខ្លាំងពីប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ។ គំរោង ARTIP ផ្តល់ប្រឹក្សា និងគាំទ្រដល់រដ្ឋាភិបាលទាំងអស់ ក្នុងការបង្កើត និង/ឬ កែប្រែ ក្របខ័ណ្ឌច្បាប់ជាតិពាក់ព័ន្ធនឹងបញ្ហាជួញដូរមនុស្ស ។ គំរោង ផ្តោតលើសពីច្បាប់ជួញដូរមនុស្សទៅទៀត ដូចជា ច្បាប់ពាក់ព័ន្ធ ទៅនឹងការលាងលុយកខ្វក់ នីតិវិធីជំនួយខាងផ្នែកច្បាប់ឱ្យគ្នា ទៅវិញទៅមក និងបត្យាប័ន ។

គំរោង ARTIP គាំទ្រដល់ការបង្កើត និងអនុវត្តក្របខ័ណ្ឌ គោលនយោបាយខ្លាំងលើបញ្ហាជួញដូរមនុស្ស ទាំងនៅថ្នាក់ជាតិ និងថ្នាក់តំបន់ ។ អាស៊ាន គឺជាដៃគូដ៏សំខាន់សំរាប់គំរោងនៅ ថ្នាក់តំបន់ ដោយសារអាស៊ានគឺជាដើរតួនាទីជាស្នូលក្នុងការ បង្កើតស្តង់ដាររួម និងការចែករំលែកការអនុវត្តល្អៗ និង គោលនយោបាយថ្នាក់តំបន់ខ្លាំងលើបញ្ហាជួញដូរមនុស្ស ។

កម្មវិធីស្រាវជ្រាវតូចមួយ តែមានគោលដៅច្បាស់លាស់លើការ ស្រាវជ្រាវដែលមានលក្ខណៈច្នៃប្រឌិត លើវិស័យពាក់ព័ន្ធ ក្នុង ការឆ្លើយតបលើបញ្ហាជួញដូរមនុស្ស របស់ប្រព័ន្ធយុត្តិធម៌ ព្រហ្មទណ្ឌ ។





**គំរោង ARTIP ទទួលស្គាល់ពីសារៈសំខាន់នៃការធ្វើការងារជាមួយ និងតាមរយៈដៃគូ និងអ្នកពាក់ព័ន្ធ ថ្នាក់ជាតិ និងការស្វែងរកការអនុវត្តសកម្មភាពតាមរយៈកិច្ចសហប្រតិបត្តិការ និងការពិភាក្សា ។ ពត៌មានស្តីពីផែនការសកម្មភាព និងធនធាន មាននៅការិយាល័យគំរោងថ្នាក់ជាតិ និងតំបន់ ។**

**Website របស់គំរោង ARTIP បានផ្តល់បណ្តាញផ្តល់ព័តមានអំពីគំរោងទាំងអស់ រួមទាំងសកម្មភាពរបស់គំរោង ARCPPT ព្រមទាំងធនធានរបស់គំរោងនៅថ្នាក់ជាតិ ថ្នាក់តំបន់ និងអន្តរជាតិ ។**

សូមពិនិត្យផ្នែកខាងក្រោយដើម្បីទំនាក់ទំនងព័តមានលំអិត